# ការវាយតម្លៃផលប៉ះពាល់បឋមលើសេចក្តីព្រាងប្រកាស
# ស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

លេខយោង: [បញ្ចូលលេខយោងដែលមានតែមួយគត់-មូលដ្ឋានទិន្នន័យ]

កាលបរិច្ឆេទចាប់ផ្តើម : [ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤]

កាលបរិច្ឆេទបញ្ចប់ : [ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤]

## អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

(រៀបរាប់ពីចំណុចសំខាន់ៗ ដូចជាកាតព្វកិច្ច វិសាលភាព និងគោលបំណង)

ប្រកាសនេះ ចែងពីការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺឆ្លងសត្វ ការពារសុខភាពសត្វ សុខភាពសាធារណៈ និងការការពារបរិស្ថាន។ នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលមានបំណងប្រកបអាជីវកម្មចិញ្ចឹមសត្វមានកាតព្វកិច្ច ដូចខាងក្រោមៈ

- ស្នើសុំលិខិតអនុញ្ញាតបង្កើតកសិដ្ឋាន និងសុំចុះបញ្ជីកសិដ្ឋាន
- ការសាងសង់ត្រូវគោរពតាមបទដ្ឋានបច្ចេកទេស
- ធានាការអនុវត្តវិធានបសុព្យាបាល និងបទដ្ឋានបច្ចេកទេសគ្រប់គ្រាន់សម្រាប់ការចិញ្ចឹម។

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះកសិដ្ឋានចិញ្ចឹមសត្វ (ប្រភេទ«ក» ប្រភេទ«ខ» និងប្រភេទ «គ» )។

ប្រភេទបញ្ញត្តិកម្ម

*សូមគូសសញ្ញាក្នុងប្រអប់ឲ្យត្រូវនឹងប្រភេទបញ្ញត្តិកម្មណាមួយ ហើយសូមអធិប្បាយប្រសិនបើសំណើនោះជាប្រភេទផ្សេងទៀត។*

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☐ | ☑ | ☐ | ☐ | ☐ |

ផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មលើវិស័យ ៖

☑ សេដ្ឋកិច្ច □ សង្គមកិច្ច ☑ បរិស្ថាន ☑ សុខភាពសាធារណៈ

### ១. ការកំណត់បញ្ហា

*បញ្ហាមានដូចជា សុខភាពនិងសុវត្ថិភាពសាធារណៈ ការការពារ និងអភិរក្សបរិស្ថាន សមធម៌យេនឌ័រ និងសង្គម និងការអភិរក្សវប្បធម៌ ការប្រកួតប្រជែង ការប្រមូលព័ត៌មាន អនុលោមតាម កិច្ចព្រមព្រៀងអន្តរជាតិ ផ្សេងៗល។*

**១.ក. បញ្ហាចម្បងដែលបញ្ញត្តិកម្មមានបំណងដោះស្រាយ ដោយផ្តល់អំណះអំណាង (ភស្តុតាង/ភាពជាក់ស្តែង ប្រសិនបើចាំបាច់)**

| |
|---|
| ១.សុខភាព និងសុវត្ថភាពសាធារណៈ<br>សុវត្ថភាពចំណីអាហារជាកត្តាចម្បងដល់សុខភាពមនុស្ស ដែលចាំបាច់ត្រូវមានការត្រួតពិនិត្យពីផលិត ផល ដំបូងរហូតដល់ការកែច្នៃ។ កត្តានេះ និយាយដោយឡែកនៅកម្ពុជា ផលិតផលសាច់សត្វនៅមិនទាន់ ធានានូវសុវត្ថភាពដល់ការបរិភោគនៅឡើយទេ ដោយសារសាច់សត្វដែលកំពុងផ្គត់ផ្គង់នៅលើទីផ្សារមិនមាន ប្រភពចេញពីកសិដ្ឋានចិញ្ចឹមសត្វ ដែលមានវិធានបសុព្យាបាល និងបទដ្ឋានបច្ចេកទេសគ្រប់គ្រាន់។ កន្លែង ចិញ្ចឹមសត្វភាគច្រើនមិនមានលិខិតអនុញ្ញាត និងគ្មានបទដ្ឋានបច្ចេកទេសនៃការចិញ្ចឹមត្រឹមត្រូវ អាចធ្វើឲ្យសត្វមានជំងឺដូចជាជំងឺប៉េះគោ-ក្របី ជំងឺរលាកស្រោមសួតគោ-ក្របី ជំងឺប៉េះជ្រូក ជំងឺឈាមខ្មៅ ជំងឺឆ្លូត ជំងឺបូសខ្យល់ ជំងឺសាទឹក ជំងឺចុងអង្គរ និងជំងឺផ្តាសាយបក្សីជាដើម ត្រូវបានគេដឹកជញ្ជូន និងធ្វើពាណិជ្ជកម្មនៅលើទីផ្សារ។ ជំងឺទាំងនេះ មានលក្ខណៈកាចសាហាវ និងឆ្លងរាតត្បាតឆាប់រហ័សបំផុតគ្មានព្រំដែនកំណត់ជាក់លាក់ និងធ្វើ ឲ្យមានផលវិបាកខ្លាំងដល់សុខភាពសាធារណៈនិងសេដ្ឋកិច្ចសង្គម។ ជាក់ស្តែងជំងឺផ្តាសាយបក្សី យោងតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោកឆ្នាំ២០១៣ ជំងឺផ្តាសាយបក្សីបានបណ្តាលឲ្យមនុស្សស្លាប់បាត់បង់ជីវិតអស់ចំនួន៣៧នាក់ ដោយឡែកប្រទេសកម្ពុជាមានប្រជាពលរដ្ឋបានស្លាប់ចំនួន២៩នាក់ ។<br>**២.ការការពារបរិស្ថាន**<br>អ្នកចិញ្ចឹមសត្វនៅប្រទេសកម្ពុជាមានទម្លាប់ចិញ្ចឹមសត្វ ដោយគ្មានការគ្រប់គ្រងដូចជាលែងចោលពាសវាលពាសកាល រីឯការចិញ្ចឹមសត្វខ្លះទៀតមានទ្រង់ទ្រាយជាកសិដ្ឋានដែរ តែទីតាំងនៅមិនទាន់សមស្រប គ្មានបទដ្ឋានបច្ចេកទេស គ្មានការត្រួតពិនិត្យពីសមត្ថកិច្ចផលិតកម្មនិងបសុព្យាបាល បណ្តាលឲ្យប៉ះពាល់បរិស្ថានដូចជា ក្លិនស្អុយពីកាកសំណល់នៃការចិញ្ចឹមសត្វ បានបង្កឲ្យមានសត្វរុយ និងសត្វល្អិតផ្សេងៗទៀត ការបង្ហូរទឹកកខ្វក់ សម្លេងសត្វស្រែក ការចម្លងមេរោគតាមខ្យល់។ល។ ធ្វើឲ្យប៉ះពាល់ដល់អ្នករស់នៅជិតខាង (ការចុះសម្ភាសន៍ផ្ទាល់ជាមួយសមត្ថកិច្ចផលិតកម្មនិងបសុព្យាបាល និងប្រជាពលរដ្ឋពាក់ព័ន្ធ)។ ទន្ទឹមនឹងនេះដែរ តាមរយៈនៃការជួបពិគ្រោះយោបល់ជាមួយសមត្ថកិច្ចមូលដ្ឋាន និងមន្ត្រីជំនាញបសុព្យាបាលនៅខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្តព្រៃវែងបានឲ្យដឹងថា មានប្រជាពលរដ្ឋដែលបានចូលរួមក្នុងវេទិកាសាធារណៈជាច្រើន បានសំណូមពរដល់អាជ្ញាធរមានសមត្ថកិច្ចឲ្យមានវិធានការដោះស្រាយ ចំពោះកសិដ្ឋានចិញ្ចឹមសត្វមានបរិស្ថាន មិនសមស្រប(ដូចជាមានក្លិនស្អុយ មានរុយច្រើន កាកសំណល់ បង្ហូរចូលប្រឡាយទឹកជាដើម...) ។<br>៣.ការប្រកួតប្រជែង |

ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ និងការចិញ្ចឹម សម្រាប់ធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋលើកទឹកចិត្ត មិនមានការហាមប្រាមឬរឹតបន្តឹងទេ តែការចិញ្ចឹមសត្វហាក់នៅមានកម្រិតនៅឡើយ។ បរិមាណផ្គត់ផ្គង់សាច់សត្វរបស់កម្ពុជាសម្រាប់តម្រូវការហូបចុកនៅក្នុងប្រទេសនៅមិនទាន់គ្រប់គ្រាន់នៅឡើយ ដែលចាំបាច់តម្រូវឲ្យមានការនាំចូលសាច់សត្វ សត្វរស់និងស៊ុតពីក្រៅប្រទេស។ ដូច្នេះ សមត្ថភាពប្រកួតប្រជែងលើការចិញ្ចឹមសត្វនៅកម្ពុជា នៅទន់ខ្សោយ ដោយសារថ្លៃដើមនៃការចញ្ចឹមមានកម្រឹតខ្ពស់ មិនអាចប្រកួតជាមួយសាច់សត្វ ដែល នាំចូលពីក្រៅប្រទេសបាន ឧទាហរណ៍ជ្រូកសាច់នាំចូលពីប្រទេសជិតខាងកម្ពុជា មានតម្លៃថោកជាងជ្រូកសាច់ ដែលបានចិញ្ចឹមនៅក្នុងស្រុក។ ករណីថ្លៃដើមនៃការចញ្ចឹមមានកម្រឹតខ្ពស់ ដែលបណ្តាលមកពីកត្តាពូជ ចំណី និងកត្តាបច្ចេកទេសនៃការចិញ្ចឹមនោះ ម្យ៉ាងទៀតលំហូរនៃ ការនាំចូលសាច់សត្វ សត្វរស់និងស៊ុតពីក្រៅប្រទេស បានកំពុងធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានដល់ការចិញ្ចឹមសត្វក្នុងស្រុក។ (កិច្ចសម្ភាសន៍ ជាមួយសមត្ថកិច្ចផលិតកម្មនិងបសុព្យាបាលនិងអ្នកចិញ្ចឹម សត្វនៃខេត្តកំពង់ស្ពឺ ព្រៃវែង និងខេត្ត កំពង់ឆ្នាំង ) ។

កង្វះខាតបទដ្ឋានគត្តិយុត្តពាក់ព័ន្ធនឹងការចិញ្ចឹមសត្វ ក៏ជាឧបសគ្គដល់ការវិនិយោគលើការចិញ្ចឹមសត្វផងដែរ ហើយអាចធ្វើឲ្យប្រទេសកម្ពុជាបាត់បង់សមត្ថភាពប្រកួតប្រជែងជាអន្តរជាតិលើការនាំចេញសាច់សត្វ ឬសត្វ។ តាមទិសដៅសមាហរណកម្មអាស៊ានឆ្នាំ២០១៥ ប្រទេសអាស៊ាននីមួយៗ តម្រូវឲ្យមានច្បាប់ស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនិងលិខិតបញ្ជាក់ការអនុវត្តល្អប្រសើរនៃកសិដ្ឋានចិញ្ចឹមសត្វ ( Good Animal Husbandry Practice ) ទើបអាចធ្វើអាជីវកម្មនាំចេញសាច់សត្វ ឬសត្វទៅលក់នៅក្នុងតំបន់អាស៊ានបាន ( កិច្ចសម្ភាសន៍ជាមួយនឹងមន្ត្រីមានសមត្ថកិច្ច នៃ នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល)។

### ៤.ការគ្រប់គ្រងព័ត៌មាននិងទិន្នន័យនៃការចិញ្ចឹមសត្វ

នាយកដ្ឋានក៏ដូចជាក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ កំពុងជួបការលំបាកលើការគ្រប់គ្រងព័ត៌មាន និងទិន្នន័យនៃការចិញ្ចឹមសត្វ ដោយក្តាប់មិនបានពីស្ថិតិសត្វនិងស្ថានភាពជំងឺសត្វ ពិសេសការប្រមូលទិន្នន័យសម្រាប់កសាងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរបស់ក្រសួងក្នុងវិស័យសត្វ។ ទន្ទឹមនឹងនេះ ព័ត៌មានពាក់ព័ន្ធនឹងជំងឺឆ្លងសត្វ ក៏មានការប្រឈមក្នុងគ្រប់គ្រង ដោយសារការចិញ្ចឹមពុំមានលក្ខណៈប្រមូលផ្តុំ ដោយពុំមានច្បាប់ទម្លាប់ត្រឹមត្រូវ ។

**១.ខ. បញ្ហាពាក់ព័ន្ធផ្សេងទៀតដែលបញ្ញត្តិកម្មអាចជួយដោះស្រាយផងដែរ ដោយផ្តល់អំណះអំណាង (ភស្តុតាង/ភាពជាក់ស្តែង ប្រសិនបើចាំបាច់)**

-ប្រជាពលរដ្ឋពុំសូវមានទំនុកចិត្តលើការចិញ្ចឹមសត្វ ដោយខ្វះបច្ចេកទេសក្នុងការចិញ្ចឹម

-គ្មានលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបើកកសិដ្ឋានចិញ្ចឹមសត្វ ធ្វើឲ្យអ្នកវិនិយោគមិនសម្រេចចិត្តវិនិយោគលើវិស័យចិញ្ចឹមសត្វ

-លំបាកក្នុងដឹកជញ្ជូនសត្វក្នុងគោលបំណងពាណិជ្ជកម្ម ។

**១.គ. សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដែលពាក់ព័ន្ធ ឬប្រហាក់ប្រហែល។**
**ចូរបញ្ជាក់ថា តើហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តទាំងនេះមិនទាន់គ្រប់គ្រាន់?**

១.អនុក្រឹត្យលេខ១៦ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
២.ប្រកាស ស្តីពីការបង្កើតគណៈកម្មាធិការចុះបញ្ជីការ និងការផ្តល់លិខិតអនុញ្ញាតសេវាកម្ម ផលិតកម្ម និង បសុព្យាបាល
៣.ប្រកាសលេខ២២៧ប្រក.កសក ចុះថ្ងៃទី២៣/០៦/២០០៨ ស្តីពីបែបបទនៃការត្រួតពិនិត្យអនាម័យ សត្វនិងផលិតផលមានដើមកំណើតពីសត្វ ក្នុងស្រុក
៤.អនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់និងផលិតផលសត្វ
៥.ប្រកាសស្តីពីការគ្រប់គ្រង និងការដាក់ឲ្យប្រើប្រាស់ស្លាកលេខសម្គាល់សត្វចតុប្បាទ
៦.សេចក្តីណែនាំលេខ០១ សណន ស្តីពីការបង្កើនប្រសិទ្ធិភាពគ្រប់គ្រងផលិតកម្មសត្វ និងផលិតផលមានដើមកំណើតពីសត្វ។

ទោះបីក្រសួងមានលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យផលិតកម្មនិងបសុព្យាបាលក៏ពិតមែន តែលិខិតបទដ្ឋានទាំងនោះ នៅមិនទាន់ឆ្លើយតបនឹងតម្រូវការនៃស្ថានការអភិវឌ្ឍន៍វិស័យចិញ្ចឹមសត្វនៅឡើយទេ។ ដើម្បីវត់ឲ្យទាន់សភាពការណ៍ក្នុងតំបន់ ពិសេសគោលដៅពាណិជ្ជកម្មនៃតំបន់អាស៊ាន បានកំពុងតម្រូវឲ្យកម្ពុជាពង្រឹងសមត្ថភាពក្នុងក្របខ័ណ្ឌច្បាប់ ទើបអាចមានសមត្ថភាពប្រកួតប្រជែងសេដ្ឋកិច្ចទាំងក្នុងតំបន់ និងទាំងនៅកម្រិតអន្តរជាតិបាន។

**១.ឃ. តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ?**
(ប្រសិនបើមាន សូមពន្យល់)

ពុំមានប៉ះពាល់ដល់ការប្រកួតប្រជែងទេ ។

**២. គោលបំណង** - តើយើងចង់សម្រេចបានអ្វី?
*ចូរបញ្ជាក់អំពីគោលបំណង (លទ្ធផល) ចុងក្រោយ មិនមែនគ្រាន់តែជាលទ្ធផលភ្លាមៗ ឬជាមធ្យោបាយនោះទេ។ (សូមជៀសវាងការលើកឡើងអំពីមធ្យោបាយដើម្បីសម្រេចគោលបំណងនៅចំណុចនេះ)។*

*មិនត្រូវកំណត់គោលបំណងឲ្យចង្អៀតពេកទេដែលរឹតត្បិតជម្រើស តែក៏មិនត្រូវឲ្យទូលំទូលាយពេកឬមិនច្បាស់លាស់ដែលនឹងធ្វើឲ្យការវិភាគមានការលំបាក។ សូមផ្សាភ្ជាប់ទៅ នឹងគោលបំណងនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ប្រសិនបើពាក់ព័ន្ធ។ ការគៀរគរចំណូលឬបង្កើតឥទ្ធិពល សម្រាប់ស្ថាប័ន មិនមែនជាគោលបំណងសមស្របរបស់បញ្ញត្តិកម្មទេ។*

ដើម្បីបង្កើនផលិតភាពសត្វ ទប់ស្កាត់ការរីករាលដាលជំងឺសត្វ ការពារសុខភាពសត្វ សុខមាលភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន ។

### ៣. ជម្រើស

ជម្រើសផ្សេងៗរួមទាំងសំណើបញ្ញត្តិកម្ម (សម្រាប់ការវិភាគលើផលប៉ះពាល់ )

*( ពិចារណាករជម្រើសផ្សេងទៀតជាការសំខាន់ ហើយសូមកត់សម្គាល់ថាបញ្ញត្តិកម្មមិនមែនជាជម្រើស ដំបូងបង្អស់នោះទេ )*

| |
|---|
| ១. សំណើបញ្ញត្តិកម្ម : សេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ។ |
| ២. ពង្រឹងការអនុវត្តលិខិតបទដ្ឋានមានស្រាប់ ដោយលើកកម្ពស់ការយល់ដឹងអំពីការចិញ្ចឹមសត្វ ។ |

### ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពាកកិច្ច និងផលចំណេញ

#### ៤.១. ការកំណត់ភារកិច្ច និងប្រភេទបន្ទុកចំណាយ (tasks and cost-categories)

*តារាងខាងក្រោមនេះគ្រាន់តែរំលេចពីប្រភេទបន្ទុកចំណាយតែប៉ុណ្ណោះ ពុំចាំបាច់ការគណនា លម្អិតទេ។*

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| សំណើបញ្ញត្តិកម្មៈ ……… | រៀបចំប្រកាសថ្មី | |
| ជម្រើសទី១:ប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ | ១.ការរៀបចំសេចក្តីព្រាង<br>២.ពិគ្រោះយោបល់<br>៣.ការចេញលិខិតអនុញ្ញាត និងផលិតឯកសារ ( ពាក្យសុំបង្កើតនិងចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ)<br>៤.ការចុះត្រួតពិនិត្យនិងធ្វើវិធានបសុពេទ្យ ៥.តាមដានការអនុវត្តរបស់ កសិដ្ឋាន<br>៦.ការងារគ្រប់គ្រងទិន្នន័យ<br>៧.ការងារផ្សព្វផ្សាយ | ១.ការចូលរួមពិគ្រោះយោបល់<br>២.សុំលិខិតអនុញ្ញាតបង្កើតកសិដ្ឋាន ចិញ្ចឹមសត្វ<br>៣.សុំចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ<br>៤.ជ្រើសរើសទីតាំងនិបង្កើតហេដ្ឋារចនាសម្ព័ន្ធកសិដ្ឋានចិញ្ចឹមសត្វ<br>៥.សេវាកម្មត្រួតពិនិត្យអនាម័យសត្វ និងសុខភាពសត្វ<br>៦.វិញ្ញាបនបត្រអនាម័យសត្វ<br>៧.ចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយ<br>៨.ចូលរួមក្នុងដំណើរការត្រួតពិនិត្យរបស់សមត្ថកិច្ច ។ |
| ជម្រើសទី២: ពង្រឹងការអនុវត្តលិខិតបទដ្ឋានមានស្រាប់ ដោយលើកកម្ពស់ការយល់ដឹងអំពី ការចិញ្ចឹមសត្វ ។ | ១.ប្រជុំផ្សព្វផ្សាយដល់អ្នក ចិញ្ចឹមសត្វ<br>២.ផ្សព្វផ្សាយតាមវិទ្យុ<br>៣.ចុះត្រួតពិនិត្យតាមកសិដ្ឋាន | ១.ចូលរួមក្នុងដំណើរការផ្សព្វផ្សាយ<br>២.បង្កើតកសិដ្ឋានថ្មី<br>៣.ការធ្វើបដិសណ្ឋារកិច្ច ចំពោះការអនុវត្ត ច្បាប់ដោយមន្រ្តីបសុព្យាបាលមានសមត្ថកិច្ច ។ |

| | | |
|---|---|---|
| | ៩.ផលិតឯកសារនិងបោះពុម្ពឯកសារ និងរូបភាពផ្សព្វផ្សាយ ។ | |

### ៤.២. ការកំណត់ប្រភេទនៃផលចំណេញ (benefit-categories)

*តារាងខាងក្រោមនេះរំលេចពីប្រភេទផលចំណេញ។*

| ជម្រើស | ប្រភេទនៃផលចំណេញ |
|---|---|
| សំណើបញ្ញត្តិកម្ម:សេចក្តីព្រាងប្រកាស ស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ។ | |
| ជម្រើសទី១:សំណើបញ្ញត្តិកម្ម : សេចក្តីព្រាងប្រកាស ស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ។ | - ការពារបរិស្ថាន និងទប់ស្កាត់បាននូវការរីករាលដាលនៃជំងឺឆ្លងពីសត្វទៅសត្វ និងពីសត្វទៅមនុស្ស<br>-ធ្វើឱ្យសាច់សត្វមានសុវត្ថិភាព និងបង្កើនទំនុកចិត្តរបស់អ្នកប្រើប្រាស់<br>-បង្កើនសមត្ថភាពប្រកួតប្រជែង នៃការចិញ្ចឹមសត្វក្នុងស្រុក ដើម្បីបំពេញតម្រូវការផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងឈានទៅដល់នាំចេញនៅពេលអនាគត<br>-ធ្វើឱ្យមានប្រសិទ្ធភាព ដល់ការគ្រប់គ្រង ស្ថិតិកសិដ្ឋានចិញ្ចឹមសត្វ និងបរិមាណសត្វ<br>- បង្កើតការងារក្នុងស្រុកជូនប្រជាពលរដ្ឋខ្មែរ<br>-បង្កើនទំនុកចិត្តដល់ការវិនិយោគក្នុងវិស័យចិញ្ចឹមសត្វ<br>-ងាយស្រួលដល់ការងារគ្រប់គ្រងចំណូលក្នុងវិស័យសត្វ។ |
| ជម្រើសទី២:ពង្រឹងការអនុវត្តលិខិតបទដ្ឋានមានស្រាប់ ដោយលើកកម្ពស់ការយល់ដឹង អំពីការចិញ្ចឹមសត្វ ។ | ជម្រើសទីពីរនេះ មានផលចំណេញបន្តិចបន្តួច ត្រង់អ្នករកស៊ីចិញ្ចឹមសត្វដែលមានស្រាប់ មិនបានរងនូវបន្ទុកចំណាយលើបែបបទសុំលិខិតអនុញ្ញាតនានាទេ។ |

### ៤.៣. វិសាលភាពនៃជម្រើសនីមួយៗ

***ចូររៀបរាប់អំពីវិស័យ ឬប្រភេទធុរកិច្ចដែលរងឥទ្ធិពល ព្រមទាំងធ្វើការព្យាករផលប៉ះពាល់ពីការអនុវត្តតាមជម្រើសដែលបានស្នើឡើង (សូមផ្តល់ភស្តុតាងដើម្បីគាំទ្រការប៉ាន់ស្មាននេះ)។***

| ជម្រើស | វិស័យ ឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|

| | | | |
|---|---|---|---|
| សំណើបញ្ញត្តិកម្ម: សេចក្តីព្រាងប្រកាស ស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ។ | | | |
| ជម្រើសទី១:សេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ។ | កសិដ្ឋានចិញ្ចឹមសត្វ | ១៣១២ | -របាយការណ៍ឆ្នាំ២០១១<br>-ការចុះពិគ្រោះយោបល់ |
| ជម្រើសទី២: ពង្រឹងការអនុវត្តលិខិតបទដ្ឋានមានស្រាប់ ដោយលើកកម្ពស់ការយល់ដឹង អំពីការចិញ្ចឹមសត្វ ។ | កសិដ្ឋានចិញ្ចឹមសត្វ | ១៩២ | -របាយការណ៍ឆ្នាំ២០១១<br>-ការចុះពិគ្រោះយោបល់ |

## ៥. **កិច្ចពិគ្រោះយោបល់បឋម**( ជាមួយអ្នកពាក់ព័ន្ធ )

កិច្ចពិគ្រោះយោបល់នេះមានគោលបំណងធ្វើឲ្យចំណុចខាងលើកាន់តែប្រសើរឡើង។ កិច្ចពិគ្រោះយោបល់ជាមួយសំណាក (Sample) នៃអ្នកពាក់ព័ន្ធ។ សូមធ្វើជារបៀបការប្រជុំប្រមូលគំនិត ( brainstorming session ) ឬការពិគ្រោះយោបល់ជាក្រុមជំនាញ ( focus group interviews )។ កិច្ចពិគ្រោះយោបល់លម្អិតអាចធ្វើឡើងតាមក្រោយ ប្រសិនបើតម្រូវឲ្យមាន FIA ។

> ដើម្បីមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការវិភាគ និងវាយតម្លៃអំពីផលប៉ះពាល់លើសេចក្តីព្រាងប្រកាស ស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនេះ ក្រុម RIA របស់ក្រសួង បានធ្វើការពិគ្រោះយោបល់ដូចតទៅ៖
>
> ១-ពិភាក្សាជាមួយក្រុម ORIA ប្រចាំECOSSOC នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងមួយខែចំនួន៤ដង។
>
> ២-ពិគ្រោះយោបល់ជាមួយប្រធានការិយាល័យផលិតកម្មនៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលចំនួន២ដង និងជាមួយអគ្គលេខាធិការរងនៃក្រសួងចំនួន១ដង។
>
> ៣-ចុះពិគ្រោះយោបល់ជាមួយប្រធានការិយាល័យតាមមន្ទីរកសិកម្ម និងជាមួយអ្នកចិញ្ចឹមសត្វនៅខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្តព្រៃវែង (បានជួបម្ចាស់កសិដ្ឋានប្រភេទ ក ចំនួន២ ប្រភេទ ខ ចំនួន៦ និងកសិដ្ឋានមិនមានចំណាត់ថ្នាក់ចំនួន១២កសិដ្ឋាន ) ។

## ៦. សន្និដ្ឋាន

តាមការវិភាគអំពីបន្ទុកចំណាយលើជម្រើសទី១នេះឃើញថា កសិដ្ឋានចិញ្ចឹមសត្វទាំងបីប្រភេទ (ប្រភេទ ក,ខ,គ ស្មើនឹង១៣១២កសិដ្ឋាន)បានចំណាយអស់ចំនួន ៣៥.៥៤០.៦៧០ ដុល្លារ ស្មើនឹង៩៧,២៨% នៃបន្ទុកចំណាយសរុប៣៦.៥៣៩.៨៨៩ដុល្លារ ដែលកសិដ្ឋានមួយ ត្រូវចំណាយជាមធ្យម ២៧.០៨៩ដុល្លារ ។ ដោយឡែកសម្រាប់កសិដ្ឋានប្រភេទ **ក** និង **ខ** ចំនួន១៩២កសិដ្ឋាន ដែលមានការចំណាយច្រើនលើការសាងសង់ហេដ្ឋា រចនាសម្ព័ន្ធ បើគិតជាមធ្យមក្នុងឆ្នាំដំបូងកសិដ្ឋានមួយចំណាយអស់៩៦.១៣៣ដុល្លារ។ រីឯប្រភេទ **គ** មានការចំណាយតិចតួចលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ តែកសិដ្ឋានប្រភេទនេះមានចំនួនច្រើន។

ទោះបីការចំណាយសរុបរបស់ធុរកិច្ចមានចំនួនច្រើនក៏ពិតមែន តែប្រភេទ **ក** និង **ខ** ចំណាយ៥២% ឯប្រភេទ **គ** ចំណាយអស់រហូតដល់ ៤៨%។ កសិដ្ឋានប្រភេទ **ក** និងខ ដែលចំណាយអស់៩៦.១៣៣ដុល្លារ ជាមធ្យម គឺជាការចំណាយក្នុងឆ្នាំដំបូងតែប៉ុណ្ណោះ។ ដូច្នេះ បើដកការចំណាយលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការចំណាយរបស់កសិដ្ឋានប្រភេទ ក និង ខ នៅសល់ត្រឹមតែ៦.១៣៣ដុល្លារ ហើយអាចធ្វើអាជីវកម្មជារៀងរហូតដោយគ្រាន់តែសុំបន្តលិខិតអនុញ្ញាតក្នុងពេល៥ឆ្នាំម្តង ( រីឯបន្ទុកចំណាយលើការសុំលិខិតអនុញ្ញាតវិញធុរកិច្ចចំណាយក្នុង១ឆ្នាំតែ៤០ដុល្លារសម្រាប់ប្រភេទ ក និង ២០ដុល្លារសម្រាប់ប្រភេទ ខ ដែលជាចំណាយមួយទាប)។

ផលចំណេញនៃជម្រើសទី១បើធៀបនឹងការចំណាយមានច្រើនលើសលុបៈ

១-ការពារបរិស្ថាន និងទប់ស្កាត់បាននូវការរីករាលដាលនៃជំងឺឆ្លងពីសត្វទៅសត្វ និងពីសត្វទៅមនុស្ស

២-ធ្វើឱ្យសាច់សត្វមានសុវត្ថភាព និងបង្កើនទំនុកចិត្តរបស់អ្នកប្រើប្រាស់

៣-បង្កើនសមត្ថភាពប្រកួតប្រជែង នៃការចិញ្ចឹមសត្វក្នុងស្រុក ដើម្បីបំពេញតម្រូវការផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងឈានទៅដល់ការនាំចេញនៅពេលអនាគត

៤-ធ្វើឱ្យមានប្រសិទ្ធភាព ដល់ការគ្រប់គ្រង ស្ថិតិកសិដ្ឋានចិញ្ចឹមសត្វ និងបរិមាណសត្វ

៥- បង្កើតការងារក្នុងស្រុកជូនប្រជាពលរដ្ឋខ្មែរ

៦-បង្កើនទំនុកចិត្តដល់ការវិនិយោគក្នុងវិស័យចិញ្ចឹមសត្វ

៧-ងាយស្រួលដល់ការងារគ្រប់គ្រងចំណូលក្នុងវិស័យសត្វ។

តាមការវិភាគអំពីបន្ទុកចំណាយលើជម្រើសទី២ ឃើញថា កសិដ្ឋានចិញ្ចឹមសត្វទាំងបីប្រភេទ (ប្រភេទ ក,ខ,គ ស្មើនឹង១.៣១២កសិដ្ឋាន)បានចំណាយអស់ចំនួន ៧៨.៨០០ដុល្លារ ស្មើនឹង៦០%នៃបន្ទុកចំណាយសរុប១៣១.៥៦៩ដុល្លារនៃជម្រើសទី២ ដែលកសិដ្ឋានមួយ ត្រូវចំណាយជាមធ្យម៦០ដុល្លារដែលជាចំណាយតិចតួចស្ដួចស្តើងបំផុត តែផលចំណេញសម្រាប់សង្គមវិញ ក៏តិចតួចដែរដោយរងនូវគុណវិបត្តិមួយចំនួនៈ

- សមត្ថភាពប្រកួតប្រជែងមានកម្រិតទាប ដែលអាចជាឧបសគ្គក្នុងដំណើរការសមាហរណកម្មអាស៊ាន
- បរិស្ថាន និងការរីករាលដាលនៃជំងឺឆ្លងពីសត្វទៅសត្វនិងពីសត្វទៅមនុស្សរងហានិភ័យខ្ពស់
- ការគ្រប់គ្រងផលិតកម្ម និងស្ថិតិសត្វ មិនសមស្របនឹងកម្រិតអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន
- ការបង់ចំណូលពីការចិញ្ចឹមសត្វ ទៅក្នុងថវិកាជាតិមិនច្បាស់លាស់ ។

ជម្រើសទី១ មានផលចំណេញលើសលុបធៀបនឹងជម្រើសទី២។ ដូច្នេះ ប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វត្រូវតែមាន។

. តើចាំបាច់ធ្វើ FIA ដែរឬទេ?

☐ចាំបាច់ - *សូមបញ្ចប់ការវាយតម្លៃផលប៉ះពាល់បឋម ( PIA ) ហើយចាប់ផ្តើមរៀបចំការវាយតម្លៃផលប៉ះពាល់ពេញលេញFIA បើសិនជាការប៉ាន់ស្មានបឋមលើបន្ទុកចំណាយមានតម្លៃចាប់ពី១លានដុល្លារអាមេរិក ( សូមបញ្ជាក់ថា បន្ទុកចំណាយនេះគ្រាន់តែជាលក្ខណៈវិនិច្ឆ័យមួយប៉ុណ្ណោះក្នុងចំណោមលក្ខណៈវិនិច្ឆ័យផ្សេងៗទៀត។ ក្នុងករណីបន្ទុកចំណាយតូចជាងនេះ ឬបន្ទុកចំណាយមានភាពស្មុគ្រស្មាញពេកពិបាកគណនា ប៉ុន្តែផលប៉ះពាល់មានវិសាលភាពធំ ប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែង ក៏តម្រូវឲ្យរៀបចំ FIA ផងដែរ។)*

☐មិនចាំបាច់ - *សូមផ្តល់អំណះអំណាងនិងបំពេញការវាយតម្លៃផលប៉ះពាល់បឋម (PIA) ដែលនៅសេសសល់។ (នេះត្រូវផ្តែកទៅលើកម្រិតនៃភាពសំខាន់នៃចំណាយកាតព្វកិច្ចបន្ថែម និងផលចំណេញហើយពិចារណាផង ថាតើមានផលប៉ះពាល់ដល់ការប្រកួតប្រជែងដែរឬទេ)។*

| |
|---|
| យោងតាមការវិភាគអំពីបន្ទុកចំណាយនៃជម្រើសទី១ ការវាយតម្លៃបឋម(PAS)នេះ មិនចាំបាច់ឈានទៅរកការវាយផលប៉ះពាល់តម្លៃពេញលេញទេ(*FIA*)។ |

## ៧. ការអនុវត្ត និងការតាមដាន

ប្រសិនបើជម្រើសបញ្ញត្តិកម្មត្រូវបានជ្រើសរើសះ

**៧.១.**តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

| |
|---|
| ក្នុងអំឡុងពេលនៃការប្រតិបត្តិបញ្ញត្តកម្មនេះ ដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អ ត្រូវឲ្យមានការចុះធ្វើអធិការកិច្ចបួនដងក្នុងមួយឆ្នាំ ក្នុងនោះមានការចុះពិនិត្យតាមដានដោយមន្ត្រីមានសមត្ថកិច្ចថ្នាក់រាជធានីខេត្តចំនួនបីដងនិងការធ្វើអធិការកិច្ចដោយថ្នាក់ក្រសួងចំនួនមួយដងប្រចាំឆ្នាំនីមួយៗ ព្រមទាំងពង្រឹងសមត្ថភាពមន្ត្រីជំនាញ។ |

**៧.២.** តើគួរធ្វើការពិនិត្យ/តាមដានបញ្ញត្តិកម្មនេះឡើងវិញក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានប្រតិបត្តិដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះគួរត្រូវបានពិនិត្យឡើងវិញ/តានដានយ៉ាងដូចម្តេច និងនៅពេលណា?

| |
|---|
| បញ្ញត្តិកម្មនេះ នឹងត្រូវត្រួតពិនិត្យឡើងវិញក្នុងរយៈពេល ៥ឆ្នាំ ។ |

## អត្ថាធិប្បាយផ្សេងទៀត

| |
|---|
| បញ្ញត្តិកម្មនេះមានសារសំខាន់ និងចាំបាច់បំផុត ក្នុងបរិបទសេដ្ឋកិច្ចសម័យបច្ចុប្បន្ន ដែលកម្ពុជាត្រូវតែពង្រឹងក្របខ័ណ្ឌច្បាប់ និងបង្កើនសមត្ថភាពភាពប្រកួតប្រជែងក្នុងវិស័យផលិតកម្មសត្វ ក្នុងលក្ខខណ្ឌសាមាហរណកម្មសេដ្ឋកិច្ចជាតិក្នុងតំបន់ និងសកលលោក។ |

| ដំណើរការ | ឈ្មោះ | មុខងារ | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|---|---|
| រៀបចំដោយ (ក្រសួងកសិកម្ម) | ១.លោក អ៊ុំ សារី | ប្រធានផ្នែក RIA | | |
| | ២.លោក ហាវ ផា | អនុប្រធានផ្នែក RIA | | |
| | ៣.លោក ខេង យ៉ាសិទ្ធ | សមាជិកផ្នែក RIA | | |
| | ៤.លោក អ៊ិត ភុំ | សមាជិកផ្នែក RIA | | |

| | | | | |
|---|---|---|---|---|
| ត្រួតពិនិត្យដោយ (ORIA) | លោក អ៊ឹម រដ្ឋារ៉ា | សមាជិក RIA | | |
| | លោកជំទាវ ស៊ាង សុផល្លា | សមាជិក RIA | | |
| | ឯ.ឧ. អេង រត្នមុនី | ប្រធានផ្នែក RIA | | |
| | ឯ.ឧ. ម៉ម សារិទ្ធ | ប្រធានផ្នែក CBA | | |
| ឯកភាពដោយ (ORIA) | ឯ.ឧ ប៊ិច សុខា | ប្រធានគម្រោង | | |
| បញ្ចូលទិន្នន័យដោយ | | | | |
| | | | | |
| ប្រមូលឯកសារ និងចុះស្រង់ព័ត៌មាន | ១.លោក អ៊ុំ សាវី<br>២.លោក ហាវ ផា<br>៣.លោក ខេង យ៉ាសិទ្ធ<br>៤.លោក អ៊ិត ភុំ | ប្រធានផ្នែក RIA<br>អនុប្រធានផ្នែក RIA<br>សមាជិកផ្នែក RIA<br>សមាជិកផ្នែក RIA | | |